ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០០១.........អ.ស.ហ.......

# សេចក្តីណែនាំ

# ស្តីពី

# បែបបទនៃការអនុវត្តការងាររបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**យោង៖**

- ព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧
- ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- ព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងកិច្ចប្រជុំនាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១

ក្នុងគោលបំណងធានាឱ្យការអនុវត្តការងាររបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព **អ.ស.ហ.** សូមធ្វើការណែនាំអំពីបែបបទនៃការអនុវត្តការងារដូចខាងក្រោម÷

**ទី១.** អង្គភាពក្រោមឱវាទរបស់**អ.ស.ហ.** ត្រូវរៀបចំស្នើសុំការពិនិត្យអនុម័តពីក្រុមប្រឹក្សា**អ.ស.ហ.** នូវរាល់ឯកសារឬលិខិតបទដ្ឋានគតិយុត្ត តាមបែបបទនិងនីតិវិធីរដ្ឋបាលដោយអនុលោមតាមមាត្រា៣ និងមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតជាធរមាន។

**ទី២.** អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវរៀបចំនិងស្នើសុំការពិនិត្យអនុម័តពីក្រុមប្រឹក្សា**អ.ស.ហ.** នូវរាល់លិខិតបទដ្ឋានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធស្ថាប័នឬការងារនិយ័តកម្មផ្សេងៗ ព្រមទាំងឯកសារដែលមានចរិតជាគោលនយោបាយឬយុទ្ធសាស្ត្រ របាយការណ៍វឌ្ឍនភាពការងារប្រចាំគ្រា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **អ.ស.ហ.** និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។ ការអនុវត្តថវិកាប្រចាំឆ្នាំរបស់ **អ.ស.ហ.** និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវមានរបាយការណ៍ស្តីពីការអនុវត្តថវិកាពាក់កណ្តាលឆ្នាំនិងប្រចាំឆ្នាំ ដែលត្រូវដាក់ជូនក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈប្រធាន **អ.ស.ហ.** ក្រោមកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.**។

**ទី៣.** ចំពោះកិច្ចការពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណឬការអនុញ្ញាត ការចុះបញ្ជីក្រុមហ៊ុនឬការចេញសេចក្តីសម្រេចលើការងារប្រហាក់ប្រហែលនេះ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវស្នើសុំគោលការណ៍អនុញ្ញាតជាមុនពីប្រធាន **អ.ស.ហ.** តាមបែបបទនិងនីតិវិធីរដ្ឋបាលដែលមានជាធរមាន។ ក្នុងករណីដែលកិច្ចការនេះមានការពាក់ព័ន្ធដល់ក្រសួង-ស្ថាប័នផ្សេងៗឬមានចំណុចរសើប អង្គភាពក្រោមឱវាទរបស់**អ.ស.ហ.** ត្រូវគួសរំលេចនិងបញ្ជាក់ជូនប្រធាន**អ.ស.ហ.** ដើម្បីពិនិត្យសម្រេចលើនីតិវិធីអនុម័តការងារនេះ។

**ទី៤.** ចំពោះកិច្ចការពាក់ព័ន្ធនឹងការដោះស្រាយវិវាទឬបណ្តឹងផ្សេងៗដែលជាសមត្ថកិច្ចរបស់ខ្លួន អង្គភាពក្រោមឱវាទរបស់**អ.ស.ហ.** ត្រូវរាយការណ៍និងស្នើសុំគោលការណ៍អនុវត្តជាមុនពីប្រធាន**អ.ស.ហ.** តាមបែបបទនិងនីតិវិធីរដ្ឋបាលជាធរមាន។

**ទី៥.** អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវដឹកនាំនិងធ្វើការពិនិត្យសម្រេចលើការងារប្រចាំថ្ងៃដែលជាសមត្ថកិច្ចរបស់ខ្លួនតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដោយការទទួលខុសត្រូវខ្ពស់ និងគោរពទៅតាមបែបបទរដ្ឋបាលនិងនីតិវិធីច្បាប់ជាធរមាន។ ក្នុងករណីដែលពិនិត្យឃើញថាការងារចំពោះមុខមានទំនាក់ទំនងអន្តរស្ថាប័នឬជាប់ពាក់ព័ន្ធជាមួយដៃគូជាតិឬអន្តរជាតិ ឬមានចំណុចរសើបជានយោបាយ អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវស្នើសុំគោលការណ៍អនុវត្តជាមុនពីប្រធាន **អ.ស.ហ.** ដោយគោរពទៅតាមបែបបទរដ្ឋបាលនិងនីតិវិធីច្បាប់ជាធរមាន។

អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>កន្លែងទទួល</u>

- ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.**
- និយ័តករពាក់ព័ន្ធនៃ **អ.ស.ហ.**
- អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**
- ឯកសារ-កាលប្បវត្តិ